## ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការទី២  ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា

# ការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិក្នុងបរិបទ វិមជ្ឈការ និងវិសហមជ្ឈការ


ស្រាវជ្រាវដោយ៖ លោក លី យ៉ាសាក់

ដោយមានការចូលរួមពី៖ លោក ឆន ប៉ូល

លោក នន់ អស្សាច័ន្ទ



ខែវិច្ឆិកា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្ដល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈ ការផ្ដល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្ដល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្ដល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្ដីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

## មាតិកា


១. សេចក្តីផ្តើម ........................................................................................................ 1
២. ក្របខ័ណ្ឌគតិយុត្តិដែលគាំទ្រដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ............................................ 2
៣. ការរៀបចំ និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ......................................................... 5
   ក. ថវិកាឃុំ សង្កាត់ ............................................................................................... 5
   ខ. ថវិការបស់ក្រុង ស្រុក និងរាជធានី ខេត្ត.................................................................... 8
៤. ការត្រួតពិនិត្យថវិកា និងតួនាទីរបស់សភា.......................................................................... 11
   ក. សវនកម្មផ្ទៃក្នុង ................................................................................................ 11
   ខ. សវនកម្មឯករាជ្យ.................................................................................................. 11
៥. សេចក្តីសន្និដ្ឋាន........................................................................................................ 13
ឯកសារយោង ............................................................................................................... 15

## ១. សេចក្តីផ្តើម

គោលនយោបាយវិមជ្ឈការបានក្លាយជាបញ្ហារបស់ប្រទេសជាច្រើន ជាពិសេសនៅបណ្តាប្រទេសពេលដែលកំពុងទទួលបាននូវផ្លែផ្កានៃកំណើនសេដ្ឋកិច្ច។ យោងទៅតាមបទពិសោធន៍ពីបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួនបានឲ្យដឹងថា ក្នុងខណៈពេលដែលកំពុងតែទទួលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ពួកគេក៏ប្រឈមនឹងវិសមភាពនៃការបែងចែកភាគលាភកំណើនសេដ្ឋកិច្ច នៅថ្នាក់តំបន់ និងមូលដ្ឋានផងដែរ។[1] បន្ទាប់ពីសង្គ្រាមស៊ីវិល និងភាពចលាចលដែលបានកើតឡើងអស់រយៈពេលជាច្រើនឆ្នាំត្រូវបានបញ្ចប់ កម្ពុជាបានប្រឹងប្រែងបង្កើតនូវគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ដើម្បីកសាងប្រទេសជាតិឡើងវិញ ដើម្បីធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។

ក្នុងន័យនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានក្លាយជាធាតុមួយសំខាន់នៃកំណែទម្រង់ ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលចាត់ទុកកំណែទម្រង់នេះជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ ដើម្បីធានាថា សេវាសាធារណៈកាន់តែខិតទៅជិតប្រជាពលរដ្ឋ។ គោលដៅចម្បងៗបី នៃកំណែទម្រង់នេះគឺ៖ ១) ប្រជាពលរដ្ឋអាចចូលរួមយ៉ាងសកម្ម ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ហើយតាមរយៈការចូលរួមនេះ តម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នឹងត្រូវបានយកមកគិតគូរពិចារណាយ៉ាងល្អិតល្អន់ ២) ការផ្តល់សេវាសាធារណៈពីក្រសួង ស្ថាប័នថ្នាក់ជាតិនឹងកាន់តែមានប្រសិទ្ធភាព ពីព្រោះសេវាទាំងនោះនឹងត្រូវបានផ្ទេរកាន់តែជិតនឹងប្រជាពលរដ្ឋ ៣) យន្តការមួយនឹងត្រូវបានបង្កើតឡើងក្នុងការកៀរគរធនធាននៅថ្នាក់មូលដ្ឋាន។

យោងតាមក្របខ័ណ្ឌគោលនយោបាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតពោលគឺ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តមានអាណត្តិជំរុញការអភិវឌ្ឍនៅមូលដ្ឋាន ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ។ ដើម្បីបំពេញភារកិច្ចនេះ ក្រុមប្រឹក្សាដែលកើតឡើងពីការបោះឆ្នោតត្រូវមាន ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ដើម្បីចាត់ចែងការរៀបចំផែនការ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយស្វ័យភាព តម្លាភាព គណនេយ្យភាព និងឆ្លើយតបដល់ប្រជាពលរដ្ឋ។

វិមជ្ឈការត្រូវបានបែងចែកជាបីផ្នែកដែលរួមមាន៖ វិមជ្ឈការរដ្ឋបាល វិមជ្ឈការសារពើពន្ធ និងវិមជ្ឈការនយោបាយ។[2] វិមជ្ឈការសារពើពន្ធគឺជាការផ្ទេរហិរញ្ញវត្ថុនានា ពីរដ្ឋាភិបាលកណ្តាលទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណែកឯវិមជ្ឈការរដ្ឋបាល គឺសំដៅទៅលើកម្រិតនៃស្វ័យភាពនយោបាយដែលរដ្ឋបាល

---

[1] កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩

[2] Iimi, A. (2005). Decentralization and economic growth revisited: An empirical note. Journal of Urban Economics, 57, 449-461.

ថ្នាក់ក្រោមជាតិទទួលបានពីថ្នាក់ជាតិ។ វិមជ្ឈការនយោបាយមានន័យថាកម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសិទ្ធិនយោបាយ ជាតំណាងប្រជាពលរដ្ឋ។[3]

ឯកសារស្រាវជ្រាវសង្ខេបនេះ នឹងផ្តោតសំខាន់ទៅលើវិមជ្ឈការសារពើពន្ធ ពោលគឺថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងបរិបទកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងប្រទេសកម្ពុជា។ បន្ថែមលើសពីនេះ ឯកសារនេះនឹងពិនិត្យមើលក្របខ័ណ្ឌច្បាប់នានាដែលគាំទ្រដល់ ការធ្វើប្រតិបត្តិការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងថាតើថវិកាថ្នាក់ក្រោមជាតិត្រូវបានអនុវត្តយ៉ាងដូចម្តេច ហើយសភាអាចពង្រឹងតួនាទីត្រួតពិនិត្យរបស់ខ្លួនតាមវិធីណា ដើម្បីធានាថាការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពសមស្របទៅតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនានា។

## ២. ក្របខ័ណ្ឌគតិយុត្តិដែលគាំទ្រដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

កំណែទម្រង់វិមជ្ឈការមានភាពស្មុគស្មាញ និងជាញឹកញាប់មានភាពលំបាក។ *«វិមជ្ឈការគឺជាដំណើរការមួយប្រកបដោយភាពច្នៃប្រឌិត និងផ្លាស់ប្តូរ។ គ្មានប្រទេសណាមួយ ដែលអនុវត្តបានត្រឹមត្រូវនៅពេលដែលព្យាយាមលើកដំបូង ឬលើកទី២ ឬលើកទី៣។ កាលៈទេសៈមានការប្រែប្រួល ហើយលក្ខណៈចរិកនិងការទំនាក់ទំនងអន្តររដ្ឋបាលផ្នែកសារពើពន្ធក៏មានការផ្លាស់ប្តូរដែរ។»*[4]

ម្យាងវិញទៀតភាពជោគជ័យក្នុងការ ការអនុវត្តវិមជ្ឈការ នៅក្នុងប្រទេសមួយមិនប្រាកដថាជោគជ័យនៅក្នុងប្រទេសមួយទៀតទេ។ ការអនុវត្តដោយភាពជោគជ័យគឺតែងតែពាក់ព័ន្ធជាមួយកត្តាផ្សេងៗដូចជាកត្តាប្រជាសាស្ត្រ សេដ្ឋកិច្ច វប្បធម៌។ល។

ចាប់តាំងពីឆ្នាំ២០០១ មក កម្ពុជាបានជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថាការអភិវឌ្ឍនៅមូលដ្ឋាន នឹងត្រូវបានអនុវត្តដោយគោរពតាមគោលការណ៍អភិបាលកិច្ចល្អ។

ចាប់តាំងពីចាប់ផ្តើមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនានាត្រូវបានអនុម័ត ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិមានចំណូល ឬថវិកា ដើម្បីអនុវត្តនូវអាណត្តិរបស់ពួកគេ ដូចមានចែងនៅក្នុងច្បាប់។ ក្របខ័ណ្ឌច្បាប់ទាំងនោះរួមមាន៖

[3] Schneider, A. (2003). Decentralization: Conceptualization and measurement. Studies in comparative international development , 38, 32-56.
[4] Bird, R. M and Ebel, R.D. (2001), "Fiscal Federalism and National Unity." http://www.urban.org/uploadedPDF/1000803.pdf. Retrieved: 02 Nov, 2015.

**ក.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ឆ្នាំ២០០១)**

ច្បាប់នេះត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០១ និងផ្តោតលើរដ្ឋបាលឃុំ សង្កាត់ ដែលជារដ្ឋបាលថ្នាក់ទាបបំផុតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់នេះផងដែរបានចែងនូវក្របខ័ណ្ឌនៃការគ្រប់គ្រងឃុំ សង្កាត់ ស្របទៅតាមគោលនយោបាយវិមជ្ឈការ[5] និងជាងនេះទៅទៀត ក៏បានចែងផងដែរពីធនធានដែលឃុំ សង្កាត់មានដូចជា ចំណូល ថវិកា និងទ្រព្យសម្បត្តិពីប្រភពផ្សេងៗ ដូចជារដ្ឋបាលកណ្តាល ការប្រមូលពន្ធនៅមូលដ្ឋាន ការបរិច្ចាគនានា ។ល។

**ខ.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬច្បាប់រៀបចំអង្គការ (ឆ្នាំ២០០៨)**

ច្បាប់នេះផ្តល់ស្វ័យភាពដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលធ្វើឲ្យរដ្ឋបាលទាំងនេះអាចចាត់ចែងថវិកាផ្ទាល់ខ្លួនសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មាត្រាទី ៤៩នៃច្បាប់នេះបានចែងថារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានថវិកាផ្ទាល់។ ច្បាប់នេះតម្រូវឲ្យរដ្ឋបាលទាំងនោះអនុវត្តថវិកាស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ ដែលរួមមានច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានផ្សេងៗទៀត។

**គ. ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ឆ្នាំ២០០៨)**

នៅក្នុងមាត្រាទី៣ នៃច្បាប់នេះចែងថា ច្បាប់នេះជាមូលដ្ឋានគ្រឹះមួយសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះក៏បានចែងផងដែរ អំពីរបៀបនៃការចាត់ចែងថវិកាសាធារណៈដែលរួមមានទាំង ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកា។

**ឃ. ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ**

មុននឹងច្បាប់នេះត្រូវបានអនុម័ត ក៏មានច្បាប់មួយទៀតស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត ក្រុង បានអនុម័តកាលពីឆ្នាំ១៩៩៨ ដែលច្បាប់នេះត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងឆ្នាំ២០១១ ស្របទៅតាមបរិបទថ្មីនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះមានគោលបំណងបង្កើតនូវធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងច្បាប់នេះសំដៅទៅលើរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប៉ុណ្ណោះ) ដើម្បីឲ្យមានលទ្ធភាពក្នុងការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចស្របទៅតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។

**ង. ច្បាប់ស្តីពីសវនកម្ម (ឆ្នាំ២០០០)**

មាត្រា០១ និងមាត្រា០២ នៃច្បាប់នេះបានចែងថា អាជ្ញាធរសវនកម្មជាតិត្រូវបង្កើតឡើង ដោយមានភារកិច្ចអនុវត្តសវនកម្មឯករាជ្យទៅលើស្ថាប័នរាជរដ្ឋាភិបាល ដែលរួមមានទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ

[5] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់.

ផងដែរ។[6] សវនកម្មឯករាជ្យអាចអនុវត្តលើរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រង កិច្ចប្រតិបត្តិការ និងមានប្រភេទសវនកម្មផ្សេងៗទៀត។[7]

**ច. អនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ សង្កាត់ (ឆ្នាំ២០០២)**

មូលនិធិឃុំ សង្កាត់ គឺជាមូលនិធិដែលផ្ទេរពីរដ្ឋបាលកណ្តាលទៅឃុំ សង្កាត់។ អនុក្រឹត្យនេះផ្តោតលើការបង្កើតមូលនិធិ និងគោលបំណងនៃការបង្កើតមូលនិធិនេះ ដែលអាចធ្វើឲ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តអាណត្តិ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ អនុក្រឹត្យក៏បានចែងនូវរូបមន្តនៃការបែងចែងការវិភាជន៍ថវិកាសម្រាប់ឃុំ សង្កាត់នីមួយៗ។ លើសពីនេះអនុក្រឹត្យនេះក៏បានចែងពីថាតើមូលនិធិនេះត្រូវធ្វើការចំណាយយ៉ាងដូចម្តេច។

**ឆ. អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ (ឆ្នាំ២០០២)**

អនុក្រឹត្យនេះផ្តោតលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ទាំងមូល និងចែងទាំងប្រភពចំណូល និងចំណាយរបស់ឃុំ សង្កាត់ និងជំហានក្នុងការរៀបចំ និងអនុវត្តថវិកា។

**ជ. អនុក្រឹត្យស្តីពីការបង្កើត និងការប្រព្រឹត្តទៅមូលនិធិក្រុង ស្រុក (ឆ្នាំ២០១២) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក**

អនុក្រឹត្យទាំងពីរនេះត្រូវបានបង្កើតឡើងក្នុងដំណើរការដូចមូលនិធិឃុំ សង្កាត់ ប៉ុន្តែអនុវត្តតែទៅលើក្រុង ស្រុកទេ។ មុនពេលបង្កើតមូលនិធិនេះឡើង ថវិការបស់ក្រុង ស្រុកគឺជាផ្នែកមួយនៃថវិការបស់រាជធានី ខេត្ត ប៉ុណ្ណោះ។ ជាថ្មីម្តងទៀត ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួនដោយស្វ័យភាព ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋដែលនេះជាសមិទ្ធផលថ្មីមួយទៀតនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

លើសពីក្របខ័ណ្ឌច្បាប់ដែលបានរៀបរាប់ខាងលើនេះ នៅមានប្រកាស គោលការណ៍ណែនាំ និងសៀវភៅណែនាំនានាពាក់ព័ន្ធនឹង ការគ្រប់គ្រងថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការក្នុងការចាត់ចែងការងារថវិកា។

តារាងខាងក្រោមនេះ គឺជាថវិការដ្ឋបាលថ្នាក់ក្រោមជាតិធៀបនឹងថវិកាជាតិសរុបគឺមានការកើនឡើងជាលំដាប់ ពី ៥.២៥% ឆ្នាំ២០១១ ទៅ ៦.៤២% ក្នុងឆ្នាំ២០១៣។

---

[6] ច្បាប់ស្តីពីសវនកម្មឆ្នាំ២០០០

[7] Ibid, article 3.

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសង្ខេប(គិតជាលាន ដុល្លារសហរដ្ឋអាមេរិក)

| រដ្ឋបាលថ្នាក់ក្រោមជាតិ | ឆ្នាំ2011 | ឆ្នាំ2012 | ឆ្នាំ2013 |
|---|---|---|---|
| រាជធានី ខេត្ត | 79.03 | 92.80 | 125.17 |
| ក្រុង ស្រុក | 10.37 | 14.15 | 18.43 |
| ឃុំ សង្កាត់ | 39.85 | 45.50 | 50.47 |
| សរុប | 129.25 | 152.45 | 194.07 |
| ថវិកាជាតិ | 2,462.41 | 26,92.00 | 3,023.77 |
| ភាគរយធៀបថវិកាជាតិ | 5.25% | 5.66% | 6.42% |

***** *Provincial line department budget excluded: In 2011=338.95; 2012= 393.43; 2013: 435.17*

*__ប្រភព__៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*

## ៣. ការរៀបចំ និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ដូចបានបង្ហាញខាងលើ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តអាណត្តិរបស់ពួកគេប្រកបដោយប្រសិទ្ធភាព ដូចដែលបានចែងក្នុងច្បាប់។ លើសពីនេះទៀត ចំណាយ និងចំណូល នៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានដែលបានអនុម័ត ដើម្បីធានាការអភិវឌ្ឍន៍នឹងត្រូវបានអនុវត្តតាមបែបប្រជាធិប-តេយ្យ។ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យត្រូវមានភាពតំណាងជាសាធារណៈ ស្វ័យភាពមូលដ្ឋាន ពិគ្រោះយោបល់និងការចូលរួម ឆ្លើយតបនិងគណនេយ្យភាព លើកកម្ពស់គុណភាពជីវិតពលរដ្ឋមូលដ្ឋាន លើកកម្ពស់សមធម៌ តម្លាភាព និងសេចក្តីថ្លៃថ្នូរ និងវិធានការណ៍ប្រឆាំងអំពើរពុករលួយ និងការរំលោភអំណាច។[8]

### ក. ថវិកាឃុំ សង្កាត់

### __ចំណូល__

មូលនិធិឃុំ សង្កាត់គឺជាប្រភពចំណូលសំខាន់បំផុតរបស់ឃុំ សង្កាត់នីមួយៗ។ យោងទៅតាមអនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ សង្កាត់ឆ្នាំ២០០២ មូលនិធិនេះចែកចេញជាពីរផ្នែក គឺផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍។ ផ្នែករដ្ឋបាលមិនត្រូវលើសពី១/៣ និងផ្នែកអភិវឌ្ឍន៍មិនតិចជាង ២/៣ នៃមូលនិធិសរុប។ ថវិកាផ្ទេរប្រចាំឆ្នាំពីរដ្ឋបាលកណ្តាលទៅឃុំ សង្កាត់នីមួយៗ (មូលនិធិឃុំ សង្កាត់) ត្រូវធ្វើឡើងបីដំណាក់កាលតាមលំដាប់លំដោយគឺ ៥០%, ៣០% និង២០% នៃមូលនិធិ។ ការផ្ទេរលើកដំបូងមិនត្រូវធ្វើឡើងយឺតជាងថ្ងៃទី ០១ ខែមិនា រីឯការផ្ទេរលើកទី ២ មិនត្រូវយឺតជាង ថ្ងៃទី ០១ ខែមិថុនា និងការផ្ទេរលើកទី ៣ មិនត្រូវយឺតជាងថ្ងៃទី ០១ ខែកញ្ញា។ ប្រភពចំណូលផ្សេងៗទៀតរួមមានចំណូលសារពើពន្ធ ចំណូល

[8] ច្បាប់រៀបចំអង្គការ

មិនមែនសារពើពន្ធ ចំណូលពីការបំពេញមុខងារជាភ្នាក់ងារ និងការបរិច្ចាគពីប្រជាពលរដ្ឋមូលដ្ឋាន និង អង្គការមិនមែនរដ្ឋាភិបាល។[៩]

## ចំណាយ

មាត្រាទី១៥ នៃអនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ សង្កាត់ឆ្នាំ២០០២
មូលនិធិផ្នែករដ្ឋបាលត្រូវបានប្រើសម្រាប់ការចំណាយដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភសម្រាប់ក្រុមប្រឹក្សា
- ប្រាក់ខែបុគ្គលិកនៅមូលដ្ឋាន និងចំណាយសម្រាប់បុគ្គលិកផ្សេងៗ
- ទិញ ឬជួលអាគារសម្រាប់ក្រុមប្រឹក្សា
- គ្រឿងសង្ហារឹម និងសម្ភារៈការិយាល័យសម្រាប់ ក្រុមប្រឹក្សា
- ជួសជុល និងថែទាំរដ្ឋបាលឃុំ សង្កាត់
- ថ្លៃទឹក ភ្លើង
- ទិញ ឬជួលមធ្យោបាយធ្វើដំណើរ
- ប្រេងឥន្ធនៈ ប្រេងម៉ាស៊ីន និងការថែទាំយានជំនិះ
- ផ្សេងៗទៀត

មូលនិធិសម្រាប់ផ្នែកអភិវឌ្ឍន៍គឺត្រូវចំណាយសម្រាប់គម្រោងអភិវឌ្ឍន៍មូលដ្ឋាន ដែលរួមមានគម្រោង ហេដ្ឋារចនាសម្ព័ន្ធ និងមិនមែនហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់មូលដ្ឋាន។

## ដំណើរការថវិការបស់ឃុំ សង្កាត់

ដូចថវិកាសាធារណៈដទៃទៀតដែរ ថវិកាឃុំសង្កាត់ ត្រូវអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវដំណើរការបីជំហាន ដែលរួមមានការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិកា។ ការរៀបចំថវិកា គឺត្រូវដំណើរការដូចខាងក្រោម៖ ដំបូង មេឃុំ ឬចៅសង្កាត់រៀបចំសេចក្តីព្រាងថវិកាដោយមានការគាំទ្រពី គណៈកម្មាធិការផែនការ និងថវិការបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយយកសេចក្តីព្រាងនេះដើម្បីសុំការ អនុម័តពីក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។ មេឃុំ ឬចៅសង្កាត់ត្រូវធានាថាដំណើរការនៃការរៀបចំ ថវិកាត្រូវបានធ្វើឡើងដោយការចូលរួមពីសាធារណៈជន។ ការអនុម័តថវិកានេះ មិនត្រូវធ្វើឡើងយឺតជាង ថ្ងៃទី៣១ ខែតុលានៃឆ្នាំ ដែលថវិកានោះបានពង្រាងទេ។ ទីពីរ សេចក្តីព្រាងនៃថវិកាត្រូវដាក់ជូនអភិបាល រាជធានី ខេត្ត ដើម្បីអនុម័ត។ ទោះបីយ៉ាងណាក៏ដោយ អភិបាលរាជធានី ខេត្ត មិនមានសិទ្ធិបដិសេធ ផែនការចំណាយ ដែលបានសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់នោះទេ។ ជារួម អភិបាលរាជធានី ខេត្ត

[៩] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ ឆ្នាំ២០០២

ផ្តល់ការគាំទ្រក្នុងការពិនិត្យនីត្យានុកូលភាពប៉ុណ្ណោះ។ អភិបាលរាជធានី ខេត្តនឹងផ្តល់ការបញ្ជាក់អំពីការអនុម័តនេះជាលាយល័ក្ខអក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ រតនាគារខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។ អភិបាលរាជធានី ខេត្តត្រូវអនុម័តសេចក្តីព្រាងថវិកាឃុំ សង្កាត់ នោះឲ្យបានមុនថ្ងៃទី១ ខែមករា។[10]

នៅក្នុងដំណាក់កាលអនុវត្តថវិកា ក្រុមប្រឹក្សាឃុំ សង្កាត់អាចអនុវត្តថវិការបស់ខ្លួនស្របទៅតាមច្បាប់ និងលិខិតបទដ្ឋាននានា។ រាល់ការអនុវត្តគម្រោងវិនិយោគឃុំ សង្កាត់ត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងឃុំ សង្កាត់។ ទោះបីជាយ៉ាងណាក៏ដោយ ថវិកានេះអាចត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំសារពើពន្ធ ដោយយោងទៅតាមការផ្លាស់ប្តូរលក្ខខ័ណ្ឌសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលអាចប៉ះពាល់ចំណូល និងចំណាយដែលបានព្យាករ។[11] រតនាគារខេត្តតម្រូវឲ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ប្រចាំឆ្នាំដែលទុកជាកម្មវត្ថុសម្រាប់ការធ្វើសវនកម្ម និងអធិការកិច្ច ដើម្បីធានានូវភាពជឿជាក់ តម្លាភាព និងយុត្តិធម៌ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ។ ការត្រួតពិនិត្យថវិកា និងមានការរៀបរាប់ជូនពេលក្រោយក្នុងឯកសារស្រាវជ្រាវសង្ខេបនេះ។

ជាមធ្យម គម្រោងវិនិយោគរបស់ឃុំ សង្កាត់ចំនួន ១៨00 គម្រោងទូទាំងប្រទេសក្នុងមួយឆ្នាំៗ ដែលក្នុងនោះ ៧0% គឺផ្លូវជនបទ ១៥% សម្រាប់ផ្នែកធារាសាស្ត្រ និង១៥% សម្រាប់គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដូចជាយេនឌ័រ មេរោគហ៊ីវ និងជំងឺអេដស៍ ការការពារបរិស្ថាន និងបញ្ហាផ្សេងៗទៀត។[12]

ចាប់តាំងពីឆ្នាំ២00២ រហូតមកដល់សព្វថ្ងៃនេះ ប្រភពចំណូលសំខាន់បំផុតរបស់ឃុំ សង្កាត់គឺមូលនិធិឃុំ សង្កាត់ ដែលបានវិភាជន៍រៀងរាល់ឆ្នាំពីរដ្ឋបាលកណ្តាល។ មូលនិធិឃុំ សង្កាត់មានការកើនឡើងពី២.00% ក្នុងឆ្នាំ២00៣ ដល់ ២.៨% រហូតដល់សព្វថ្ងៃនេះនៃចំណូលចរន្តរបស់ជាតិ។ មូលនិធិដែលវិភាជន៍សម្រាប់ឃុំ សង្កាត់នីមួយៗមានចំនួនប្រហែល ៤0.000 ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយឆ្នាំ។[13] ចំនួនថវិការនេះមិនអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលចេះតែកើនឡើង ហើយចំណូលផ្សេងទៀតមិនអាចពឹងផ្អែកបានឡើយ។ ឧទាហរណ៍ ច្បាប់បានចែងថាការប្រមូលពន្ធនៅមូលដ្ឋានគឺជាប្រភពចំណូលមួយក្នុងចំណោមប្រភពចំណូលនានា ប៉ុន្តែតាំងពីឆ្នាំ២00២ មក ឃុំ សង្កាត់មិនដែលមានចំណូលតាមប្រភពនេះទេ។ ជាងនេះទៅទៀត ចំណូលពីប្រភពផ្សេងទៀតដូចជាការអនុវត្តន៍មុខងារអគ្រានុកូលដ្ឋាន ក្នុងនាមក្រសួងមហាផ្ទៃ និងការចុះឈ្មោះបោះឆ្នោតក្នុងនាមគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគឺមានតិចតួច។

---

[10] Ibid. Article:11-17
[11] Ibid. Article: 18.
[12] NCDD/PID, 2012-2014.
[13] The fund allocation for CSs in 2015 by ministry of Economic and Finance.

ដោយសារថវិកាមិនគ្រប់គ្រាន់ យន្តការមួយដែលហៅថាសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកត្រូវបានរៀបចំឡើងដើម្បីកៀរគរធនធាននៅមូលដ្ឋានក្នុងការគាំទ្រដល់គម្រោងវិនិយោគឃុំ សង្កាត់ ដែលមូលនិធិឃុំ សង្កាត់មិនអាចអនុវត្តបាន។ ធនធានខាងក្រៅក្នុងការគាំទ្រគម្រោងវិនិយោគឃុំ សង្កាត់ ភាគច្រើនបានមកពីមន្ទីរវិស័យថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយ និងប្រជាពលរដ្ឋមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ ការរួមចំណែកពីអង្គការក្រៅរដ្ឋាភិបាលដែលពឹងផ្អែកតែលើមូលនិធិរបស់ខ្លួននោះ គឺជាប្រភពចំណូលមិនមាននិរន្តរភាពនោះទេ។ លើសពីនេះទៀត ការគាំទ្រពីមន្ទីរវិស័យថ្នាក់ខេត្តមានការធ្លាក់ចុះជាលំដាប់។ មន្ទីរវិស័យថ្នាក់ខេត្តទាំងនោះបារម្ភពីគម្រោងផ្ទាល់ខ្លួនរបស់ពួកគេប៉ុណ្ណោះ ជាជាងការគាំទ្រដល់គម្រោងវិនិយោគឃុំ សង្កាត់។[14] ជាងនេះទៀត ក្រុមប្រឹក្សាឃុំ សង្កាត់អាចត្រូវបានទទួលឥទ្ធិពលពីតួអង្គខាងក្រៅក្នុងការអនុវត្តថវិការបស់ខ្លួន បើទោះបីជាច្បាប់ផ្តល់នូវស្វ័យភាពដល់ឃុំ សង្កាត់ក្នុងការចាត់ចែងថវិការបស់ពួកគេ។

### ខ. ថវិការបស់ក្រុង ស្រុក និងរាជធានី ខេត្ត

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់ អនុលោមតាមច្បាប់រៀបចំអង្គការ។ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងច្បាប់នេះ ផ្តោតទៅលើតែក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ប៉ុណ្ណោះ។ ច្បាប់នេះកំណត់អំពីការប្រព្រឹត្តទៅនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ យោងតាមច្បាប់នេះ ចំណូល និងចំណាយត្រូវបានបង្ហាញដូចខាងក្រោម៖

#### <u>ចំណូល</u>

ចំណូលសម្រាប់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្តបានមកពី៖[15]

- ចំណូលមូលដ្ឋានរួមមាន ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ការបែងចែកប្រភេទ និងសមាមាត្រនៃពន្ធនៅមូលដ្ឋានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានកំណត់ដោយអនុក្រឹត្យមួយផ្សេងទៀត។ បច្ចុប្បន្ននេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានប្រគល់ភារកិច្ចរៀបចំគោលនយោបាយស្តីពីប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ[16]
- ថវិកាដែលផ្ទេរពីរដ្ឋបាលកណ្តាល ត្រូវបានបែងចែកជាពីរប្រភេទគឺមូលនិធិដែលមានភ្ជាប់លក្ខខ័ណ្ឌ និងមិនមានភ្ជាប់លក្ខខ័ណ្ឌ។
- ថ្លៃសេវាដែលទទួលបានពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងឬ ស្ថាប័ននៅថ្នាក់ជាតិ។

[14] Remarks of his H.E Hou Taing Eng, Secretary of State of Ministry of Planning during the Public Forum under the theme *“Capacity Strengthening of Commune/Sangkat Councils and Governance in Local Development”* in Takeo province, organized by Senate Region 5 on October 07, 2015.

[15] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ

[16] Annual Work Plan and Budget of NCDD 2015.

នៅក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានចេញនូវអនុក្រឹត្យស្ដីពីការបង្កើតមូលនិធិក្រុង ស្រុក ដែលជាមូលនិធិគ្មានភ្ជាប់លក្ខខ័ណ្ឌពីរដ្ឋាភិបាលកណ្ដាលសម្រាប់ក្រុង ស្រុក ដើម្បីចាត់ចែងប្រកបដោយស្វ័យភាពក្នុងការងារអភិវឌ្ឍន៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក៏ដូចជាមូលនិធិឃុំ សង្កាត់ ដែរ មូលនិធិក្រុង ស្រុកនេះក៏ត្រូវបែងចែកជាពីរផ្នែកដែរ។

**<u>ការចំណាយ</u>**

ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចំណាយដូចខាងក្រោម៖

- ប្រតិបត្តិការរដ្ឋបាល
- អនុវត្តមុខងារជាកាតព្វកិច្ច
- អនុវត្តមុខងារជាជម្រើស
- ចំណាយផ្សេងៗកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ

**<u>ដំណើរការនៃថវិកាក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត</u>**

ផែនការថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកញ្ចប់ថវិកាមួយត្រូវឆ្លងកាត់ការពិនិត្យ និងអនុម័តពីរដ្ឋសភា និងព្រឹទ្ធសភា ក្រោមច្បាប់ថវិកាប្រចាំឆ្នាំ។

ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំដោយគណៈអភិបាលនៃរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សាជាបីដំណាក់កាល។ ដំណាក់កាលទី១ ពីខែមិនា ដល់ខែឧសភា គណៈអភិបាលនៃរដ្ឋបាលនីមួយៗរៀបចំផែនការយុទ្ធសាស្ត្រនៃថវិកា និងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ បន្ទាប់មកផ្ញើរផែនការយុទ្ធសាស្ត្រនៃថវិកានោះទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុថ្នាក់ខេត្តដើម្បីបូកសរុប ផ្ញើរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទី២ ពីខែមិថុនា ដល់ខែកញ្ញា គណៈអភិបាលត្រូវរៀបចំផែនការថវិកាលម្អិតទាំងចំណូល ចំណាយ និងផ្សព្វផ្សាយផែនការនោះដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បន្ទាប់ពីការពិគ្រោះយោបល់ និងកែប្រែឡើងវិញ គណៈអភិបាលត្រូវដាក់ផែនការថវិកានេះដើម្បីទទួលការអនុម័តពីក្រុមប្រឹក្សា។ ចុងក្រោយ ពីខែតុលា ដល់ខែធ្នូ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ចូលផែនការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងសេចក្ដីព្រាងនៃច្បាប់ថវិកាជាតិប្រចាំឆ្នាំ បន្ទាប់មកដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យមុនពេលបញ្ជូនទៅសភា (រដ្ឋសភា និងព្រឹទ្ធសភា) ដើម្បីអនុម័ត។

ការអនុវត្តថវិការបស់ក្រុង ស្រុក ខណ្ឌ និងរាជធានីខេត្តត្រូវបានធ្វើឡើងតាមលំនាំដូចថវិកាឃុំ សង្កាត់ ដែរ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា។ ថវិកានេះអាចធ្វើវិសោធនកម្មក្នុងឆ្នាំនៃការធ្វើសារពើពន្ធ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលនឹងក្លាយជាកម្មវត្ថុសម្រាប់អធិការកិច្ច និងសវនកម្ម។ ចំពោះការត្រួតពិនិត្យថវិកា នឹងរៀបរាប់នៅផ្នែកបន្ទាប់នៃឯកសារស្រាវជ្រាវនេះ។

គោលដៅមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺការបង្កិតសេវាសាធារណៈឲ្យនៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន ដូច្នេះមុខងារមួយចំនួននៅក្រសួង ឬស្ថាប័នថ្នាក់កណ្តាល នឹងត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅពេលដែលមុខងារត្រូវបានផ្ទេរ ធនធានចាំបាច់ត្រូវតែផ្ទេរទៅជាមួយដែរ ដូច្នេះថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(ទាំងចំណូល និងចំណាយ) នឹងមានការកើនឡើងជាលំដាប់។ ការអនុវត្តបែបនេះ គឺស្របតាមការអនុវត្តជាអន្តរជាតិលើការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដែលណែនាំថា *«ថវិកាទៅតាមមុខងារ»*។[17]

ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតលើ ក្រុង ស្រុក សម្រាប់ធ្វើការផ្ទេរមុខងារដោយសារតែសមត្ថភាព និងទំហំនៃរដ្ឋបាលឃុំ សង្កាត់នៅមានកម្រិតនៅឡើយ។ មានគម្រោងសាកល្បងក្នុងការផ្ទេរមុខងារពីរដ្ឋ-បាលកណ្តាលដូចជាក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា ក្រសួងអប់រំយុវជន និងកីឡា ក្រសួងបរិស្ថាន និងក្រសួងសុខាភិបាល។ ក្រសួងថ្នាក់កណ្តាលដែលពាក់ព័ន្ធក្នុងផ្ទេរមុខងារសាកល្បង ដែលមានរៀបរាប់ដូចខាងក្រោម៖[18]

*ក្រសួងអភិវឌ្ឍន៍ជនបទ*

- អនាម័យជនបទ (១០ ស្រុក)
- ជួសជុលប្រព័ន្ធទឹកស្អាត (៧ ស្រុក)

*ក្រសួងអប់រំ យុវជន និងកីឡា*

- ការគ្រប់គ្រងសាលាបឋមសិក្សា
- ការអប់រំកុមារតូច
- ការអប់រំក្រៅប្រព័ន្ធ

*ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា*

- ការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅរដ្ឋបាលខេត្តបាត់ដំបង
- ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់អង្គការក្រៅរដ្ឋាភិបាល ទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបងចំនួន១០
- សេវាថែទាំសម្រាប់កុមាររងាយរងគ្រោះនៅសហគមន៍ទៅឃុំ សង្កាត់នៅក្នុងក្រុង ស្រុកចំនួន ១០

*ក្រសួងបរិស្ថាន*

- ការគ្រប់គ្រងសំរាម និងកាកសំណល់រឹងទៅក្រុង ស្រុកទូទាំងប្រទេស

*ក្រសួងសុខាភិបាល*

- មណ្ឌលសុខភាពក្នុងស្រុកចំនួន ៥ ក្នុងខេត្តបាត់ដំបង និងពោធិសាត់

---

[17] Balh, Roy. 1999. *Implementation Rules for Fiscal Decentralization.* Georgia State University: Working Paper 99-1.
[18] NCDD's Semi-Annual Report 2015.

## ៤. ការត្រួតពិនិត្យថវិកា និងតួនាទីរបស់សភា

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុនៃការធ្វើសវនកម្មឯករាជ្យ និងអធិការកិច្ច[19]។ យន្តការដែលមានស្រាប់សព្វថ្ងៃនេះពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន សវនកម្មផ្ទៃក្នុង សវនកម្មឯករាជ្យពីអជ្ញាធរជាតិសវនកម្ម ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចដែលមានលក្ខណៈឯករាជ្យរបស់ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងការធ្វើអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

### ក. សវនកម្មផ្ទៃក្នុង

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់រួមទាំងខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវបង្កើតយន្តការសវនកម្មផ្ទៃក្នុង[20] ដែលមានតួនាទីត្រួតពិនិត្យមើល និងវាយតម្លៃដោយឯករាជ្យនូវប្រសិទ្ធភាព នៃការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។[21]

ការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង សំដៅទៅលើ ការធានាឲ្យមានដូចខាងក្រោមនេះ៖[22]

ក.) ប្រសិទ្ធភាពនៃប្រតិបត្តិការ

ខ.) ភាពជឿជាក់នៃរបាយការណ៍ហិរញ្ញវត្ថុ

គ.) ការអនុវត្តតាមច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ នីតិវិធី និងការរៀបចំការអនុវត្ត។

រដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឲ្យផ្ញើរបាយការណ៍សវនកម្មផ្ទៃក្នុងទៅកាន់អជ្ញាធរជាតិសវនកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[23]

### ខ. សវនកម្មឯករាជ្យ

<u>**អជ្ញាធរជាតិសវនកម្ម**</u>

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ជាកម្មវត្ថុ នៃការធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ ដោយអជ្ញាធរជាតិសវនកម្ម។[24] កម្មវត្ថុនៃការធ្វើសវនកម្មឯករាជ្យដោយអជ្ញាធរជាតិសវនកម្មរួមមាន៖ របាយការណ៍ហិរញ្ញវត្ថុ ការពិនិត្យប្រព័ន្ធត្រួតពិនិត្យ (ដើម្បីវាយតម្លៃភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រង និងដំណើរការដែលបានបង្កើតឡើងសម្រាប់អនុវត្តសកម្មភាព) និងការវាយតម្លៃលើប្រតិបត្តិកំពុងបន្ត (វាយតម្លៃថាតើ

---

[19] See the following pieces of legislation: (1) Law on administration of province capital, (2) Sub-decree No. 172 on the financial administration system of municipalities and Sroks 2012, (3) Sub-decree No. 26 on the financial management of commune/sangkat, (4) Law on audit 2000, (5) Law on public financial system 2008, and (6) Prakas from the MEF.

[20] មាត្រា៤១ នៃច្បាប់សវនកម្មឆ្នាំ២០០២

[21] Ibid, Article 42.

[22] Ibid, Article 43.

[23] Directive No. 003 on standard for internal audit reports.

[24] មាត្រា2 នៃច្បាប់សវនកម្មឆ្នាំ២០០២

ការអនុវត្តនោះ ស្របតាមច្បាប់ និងលិខិតបទដ្ឋាន និងគោលការណ៍នានាដែរឬទេ)។[25] មិនមែនរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវបានធ្វើសវនកម្មឯករាជ្យរៀងរាល់ឆ្នាំ ដោយអជ្ញាធរជាតិសវនកម្មនោះទេ ដោយសារតែជាក់ស្តែងមានក្រសួង ស្ថាប័នរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័ន ឬភ្នាក់ងារជាច្រើនទៀត ដែលត្រូវធ្វើសវនកម្មឯករាជ្យផងដែរ ដូច្នេះមានការធ្វើសវនកម្មជាច្រើនក្នុងមួយឆ្នាំៗ។[26]

យោងទៅតាមរបាយការណ៍វាយតម្លៃផ្ទៃក្នុង ដែលបានដាក់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ អជ្ញាធរជាតិសវនកម្មអាចសម្រេចធ្វើសវនកម្មដោយដាក់ទៅក្នុងផែនការសវនកម្ម។[27] អជ្ញាធរជាតិសវនកម្មផ្ញើរបាយការណ៍សវនកម្មទៅទាំងសភា និងរដ្ឋាភិបាល។ ប្រសិនបើសភាចង់ឲ្យមានការធ្វើសវនកម្មឯករាជ្យទៅលើស្ថាប័នសាធារណៈ សភាអាចផ្ញើរសំណើផ្លូវការទៅកាន់អជ្ញាធរជាតិសវនកម្ម។ តែទោះយ៉ាងណាក៏ដោយ អជ្ញាធរជាតិសវនកម្មមានឆន្ទានុសិទ្ធិថាតើទទួល ឬបដិសេធសំណើនេះ។[28]

### ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ជាកម្មវត្ថុនៃការត្រួតពិនិត្យ និងអធិការកិច្ច អំពីការអនុវត្តថវិការបស់ពួកគេដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[29]។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺតួអង្គមួយដ៏សំខាន់ក្នុងការអភិវឌ្ឍន៍លើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា។ នាយកដ្ឋានថវិការដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើរតួនាទីសំខាន់ក្នុងដំណើរការវិមជ្ឈការ និងវិសហ-មជ្ឈការ ដូចជាការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំលិខិតបទដ្ឋាន នីតិវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការចូលរួមក្នុងការផ្ទេរអំណាច ការចាត់ចែងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការតាមដាន ការធ្វើអធិការកិច្ចការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។[30]

### ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

មន្ទីរវិស័យថ្នាក់ខេត្តទាំងអស់នៃក្រសួងថ្នាក់ជាតិ និងស្ថាប័នរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាកម្មវត្ថុនៃការធ្វើអធិការកិច្ច និងស៊ើបអង្កេតដោយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។[31] ការធ្វើអធិការកិច្ចដោយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ផ្តោតលើការគ្រប់គ្រងទ្រព្យ

[25] Ibid, article 6, 7, and 8.
[26] NAA 2011. Public Auditing Standards.
[27] NAA 2011. Public Auditing Standards.
[28] Ibid.
[29] Sub-decree No. 488 on the establishment and functioning of the Ministry of Economy and Finance 2013.
[30] Ibid.
[31] Sub-decree No. 03 on the organization and functioning of the ministry of national assembly-senate relations and inspection 2015.

សម្បត្តិរដ្ឋ ចំណូលនិងចំណាយថវិកាសាធារណៈ និងដំណើរការដែលត្រូវបានចោទប្រកាន់ថាមានអំពើពុករលួយ និងដំណើរការគ្រប់គ្រង[32] របាយការណ៍អធិការកិច្ចត្រូវផ្ញើរទៅនាយករដ្ឋមន្ត្រី។ ក្នុងអនុក្រឹត្យលេខ០៣ ឆ្នាំ២០១៥ ស្តីពីបង្កើត និងការប្រព្រឹត្តទៅក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មិនមានការរៀបរាប់ពីការធ្វើអធិការកិច្ចដល់រដ្ឋបាលថ្នាក់ក្រោមជាតិដោយក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ចទទួលយកពាក្យបណ្តឹងដោយប្រជាពលរដ្ឋ ឬសាធារណៈ ដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងធ្វើការស៊ើបអង្កេតទៅតាមបណ្តឹងទាំងនោះ។

<u>សភា</u>

សភាអាចកំណត់បញ្ហា និងចូលរួមក្នុងការត្រួតពិនិត្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈរបាយ-ការណ៍សវនកម្មប្រចាំឆ្នាំ ពាក្យបណ្តឹង និងរបាយការណ៍អធិការកិច្ចដោយក្រសួងក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច[33] របាយការណ៍សវនកម្មប្រចាំឆ្នាំរបស់អជ្ញាធរជាតិសវនកម្មអាចកំណត់បញ្ហាអំពីការអនុវត្តន៍ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់នូវអនុសាសន៍នានា។ របាយ-ការណ៍សវនកម្មរបស់អជ្ញាធរជាតិសវនកម្ម ផ្តល់នូវព័ត៌មានរួមទាំងអស់នៅថ្នាក់ជាតិ មិនបានផ្តល់ព័ត៌-មានជាក់លាក់ ឬព័ត៌មានពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិទេ។[34] តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើសភាចង់ឲ្យមានការធ្វើសវនកម្មទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយជាក់លាក់ សភាអាចធ្វើការស្នើសុំទៅកាន់អជ្ញាធរជាតិសវនកម្ម។[35]

## ៥. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្ត និងកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានតាមរយៈគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងមូលនិធិមានភ្ជាប់លក្ខខ័ណ្ឌ និងមិនភ្ជាប់លក្ខខ័ណ្ឌ និងក្របខ័ណ្ឌគតិយុត្តិជាច្រើនពាក់ព័ន្ធនឹងថវិកាថ្នាក់ក្រោមជាតិត្រូវបានដាក់ចេញ និងអនុម័តដែលអាចឲ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិកាន់តែមានស្វ័យភាពក្នុងការអនុវត្តថវិការបស់ខ្លួន និងមានគណនេយ្យភាពជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាងនេះទៅទៀត ការទទួលខុសត្រូវជាច្រើនត្រូវបានប្រគល់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្ទេរមុខងារពីក្រសួងថ្នាក់ជាតិ ដូច្នេះចំណាយសម្រាប់ការអនុវត្តមុខងារ ដែលបានផ្ទេរនឹងទៅតាមជាមួយផងដែរ

---

[32] Ibid.
[33] This is a conclusion, which results from analysis of information from sections prior to the section on parliament.
[34] See NAA's annual reports posted on its website: http://naa.gov.kh
[35] NAA 2011. Public Auditing Standards.

ដែលការអនុវត្តន៍នេះ ស្របទៅតាមការរំពឹងទុកនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជំរុញសេវាសាធារណៈឲ្យខិតកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន។

ទោះបីជាយ៉ាងណាក៏ដោយការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជួនកាលមិនត្រូវបានអនុវត្តពេញលេញទេ។ យន្តការស័ក្តិសមមួយសម្រាប់ត្រួតពិនិត្យថវិកាអាចជួយដោះស្រាយបញ្ហានេះបាន។ ការត្រួតពិនិត្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើឡើងតាមរយៈសវនកម្ម ផ្ទៃក្នុង និងឯករាជ្យ ដែលធ្វើដោយក្រសួង ឬស្ថាប័នថ្នាក់ជាតិដែលត្រូវបានប្រគល់ភារកិច្ច ដើម្បីធ្វើសវនកម្ម និងអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍៖ អជ្ញាធរជាតិសវនកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច)។ ដើម្បីទាញប្រយោជន៍ពីយន្តការនេះ និងពង្រឹងតួនាទីផ្នែកត្រួតពិនិត្យ សភាអាចប្រើប្រាស់របាយការណ៍ពាក់ព័ន្ធថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ របាយការណ៍សវនកម្មរបស់អជ្ញាធរជាតិសវនកម្ម និងរបាយការណ៍អធិការកិច្ចរបស់ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រាប់ការស៊ើបអង្កេតបន្ត។ ចុងក្រោយនេះសភាអាចស្នើសុំទៅអជ្ញាធរជាតិសវនកម្ម ធ្វើសវនកម្មឯករាជ្យលើករណីពិសេសណាមួយពាក់ព័ន្ធនឹងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៕

# ឯកសារយោង

Balh, Roy. 1999. *Implementation Rules for Fiscal Decentralization.* Georgia State University: Working Paper 99-1

Bird, R. M and Ebel, R.D. (2001). *Fiscal Federalism and National Unity*. http://www.urban.org/uploadedPDF/1000803.pdf. Retrieved: 02 Nov, 2015.

សេចក្តីណែនាំលេខ ០០៣ ស្តីពីស្តង់ដាសម្រាប់សវនកម្មផ្ទៃក្នុង

Iimi, A. (2005). *Decentralization and economic growth revisited: An empirical note*. Journal of Urban Economics, 57, 449-461.

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្តីពីសវនកម្ម ឆ្នាំ២០០០

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨

NAA 2011. Public Auditing Standards.

NAA's annual reports posted on its website: http://naa.gov.kh

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ២០១០-២០១៩

NCDD's Semi-Annual Report 2015.

Schneider, A. (2003). *Decentralization: Conceptualization and measurement*. Studies in comparative international development, 38, 32-56.

អនុក្រឹត្យលេខ ៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៥

អនុក្រឹត្យស្តីពីការបង្កើតមូលនិធិឃុំ សង្កាត់ឆ្នាំ២០០២

អនុក្រឹត្យលេខ ១៧២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ឆ្នាំ២០១២។

អនុក្រឹត្យលេខ ២៦ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

អនុក្រឹត្យលេខ ៤៨៨ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១៣